**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>ក្រសួងឧស្សាហកម្ម និងសិប្បកម្ម</u>

ភ្នំពេញ-ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦៖ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម** បានបើកប្រជុំរៀបចំយុទ្ធនាការបន្តចែកចាយទឹកស្អាតជូនប្រជាពលរដ្ឋដែលខ្វះខាតទឹកប្រើប្រាស់ ក្នុងពេលជួបគ្រោះរាំងស្ងួត នៅទីស្តីការក្រសួង។





*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

នេះជាសកម្មភាពមនុស្សធម៌ដ៏ថ្លៃថ្លារបស់ថ្នាក់ដឹកនាំក្រសួង ស្របតាមយុទ្ធនាការចែកចាយទឹកដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដើម្បីសង្គ្រោះដល់ប្រជាជនដែលកំពុងជួបបញ្ហាគ្រោះរាំងស្ងួតធ្ងន់ធ្ងរនៅតាមទីជាច់ស្រយាល និងជនបទ។ ទឹកបរិសុទ្ធដែលក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលកន្លងមក គឺជាជំនួយឧបត្ថម្ភរបស់ក្រុមហ៊ុន និងប្រតិបត្តិករផលិត និងចែកចាយទឹកស្អាតនៅកម្ពុជា តបតាមការអំពាវនាវរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** ហើយការផ្តល់ជំនួយនេះនឹងបន្តមានជាហូហែ ពិសេសបានឆ្លុះបញ្ចាំងអំពីសាមគ្គីភាព និងការបរិចាគដល់សង្គមយ៉ាងគាប់ប្រសើរបំផុតរបស់ប្រជាជនកម្ពុជាក្នុងគ្រាអាសន្ន។







*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*